**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រះសីហនុ**
**លេខ:** ០៣២៦/២១ សណ

ថ្ងៃ ពុធ ៦ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ខេត្តព្រះសីហនុ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០២១

**ជម្រាបមក**

**លោក លោកស្រី ដែលបានកំពុងរស់នៅ និងប្រកបអាជីវកម្មលើដីចំណីឆ្នេរ ស្ថិតនៅ ចំណុចពយយាយម៉ី ឆ្នេរតាបារាំង ក្នុងភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ**

**កម្មវត្ថុ៖** ស្តីពីការរុះរើសំណង់ និងការ្យផ្សេងៗ ដែលបានសង់រំលោភលើដីចំណីឆ្នេរសាធារណៈ ស្ថិតនៅ ចំណុចពយយាយម៉ី និងឆ្នេរតាបារាំង ក្នុងភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

**យោង៖**
- សារាចរណែនាំលេខ ០១សណន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការ អភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតលេខ ១៨៧/២០សណ.សសហ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់រដ្ឋបាលស្រុកស្ទឹងហាវ។

តបតាមកម្មវត្ថុ និងយោងខាងលើ រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបមក លោក លោកស្រី ជ្រាបថា ពយយាយម៉ី និងឆ្នេរតាបារាំង ជាដីរបស់រដ្ឋនិងជាលម្ហឆ្នេរសាធារណៈ ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកលំហែកាយកម្សាន្តនៅខេត្តព្រះសីហនុ។ រដ្ឋបាលខេត្តព្រះសីហនុ បានពិនិត្យឃើញថា សំណង់របស់ លោក លោកស្រី ដែលកំពុងរស់នៅ និងប្រកបអាជីវកម្មត្រង់ចំណុចពយយាយម៉ី និងឆ្នេរតាបារាំង ក្នុងភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ គឺស្ថិតនៅលើដីចំណីឆ្នេរសាធារណៈរបស់រដ្ឋ ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន អនាម័យ សណ្តាប់ធ្នាប់ និងសោភ័ណភាពឆ្នេរ។

ដូច្នេះ រដ្ឋបាលខេត្តព្រះសីហនុ សូមជូនដំណឹងដល់លោក លោកស្រី ត្រូវរុះរើសំណង់ និងការ្យផ្សេងៗ ដែលបានសង់នៅលើដីចំណីឆ្នេរសាធារណៈរបស់រដ្ឋ ស្ថិតនៅចំណុចពយយាយម៉ី និងឆ្នេរតាបារាំង **ចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះរហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ ជាកំហិត។**

ក្នុងករណីលោក លោកស្រី មិនរុះរើតាមសេចក្តីជូនដំណឹងនេះ រដ្ឋបាលខេត្តព្រះសីហនុនឹងសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលស្រុកស្ទឹងហាវ ចុះអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ ដោយមិនទទួលខុសត្រូវរាល់ការខូចខាតសម្ភារ ឬបាត់បង់ទ្រព្យសម្បត្តិរបស់បងប្អូនឡើយ។

អាស្រ័យដូចនេះ សូម លោក លោកស្រី ជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាព។

**អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ**

**គួច ចំរើន**

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា
  *"ដើម្បីគោរពជូនជ្រាប"*
- ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តព្រះសីហនុ
- រដ្ឋបាលស្រុកស្ទឹងហាវ
  *"ដើម្បីអនុវត្ត"*
- មន្ទីរព័ត៌មានខេត្តព្រះសីហនុ
  *"ដើម្បីផ្សព្វផ្សាយ"*
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន: ភូមិ៣ សង្កាត់លេខ៣ ក្រុង-ខេត្តព្រះសីហនុ អ៊ីម៉ែល: adm.shpro@gmail.com , www.sihanoukville.gov.kh